# កូនសេដ្ឋី

*បទកាគតិ*

*ញុំាអើងៗ បាយហើយកូនគេង អើងចាំចាយលុយ*
*ម៉ែឪនៅស្រុក ធ្វើមុខទុយមុយ ដាច់ខែដ្រែលុយ*
*ចងការគេថ្មី។*
*ញុំាអើងៗ បាយហើយកូនគេង អើងនឹកស្រស់ស្រី*
*សៀវភៅគ្រប់វគ្គ វលក្ខណ៍ប្រិមប្រិយ ដើរក្តីដេកក្តី*
*ស្រីសើចមិនបាត់។*
*ញុំាអើងៗ បាយហើយកូនគេង អើងជួបចាំណាត់*
*ម៉ោងប្រាំពីរព្រឹក រលឹកដុសខាត់ ចាប់លុយចែងចាត់*
*ចាយតាមក្បាលវ៉ាល់។*
*ញុំាអើងៗ បាយហើយកូនគេង អើងចាំចាក់បាល់*
*បីយ៉ាជល់មាន់ មិនគ្រាន់ប្រដាល់ លុយម៉ែបិចត្បាល់*
*អស់មិនបាច់ដឹក។*
*ញុំាអើងៗ បាយហើយកូនគេង អើងចាំជួបផឹក*
*សាច់អាំងឆារខ្វៃ ថ្ងៃសើចកក្អឹក ថើបស្រីក្លែមផឹក*
*ឬកកូនសេដ្ឋី។*

*ភ្នំពេញ ១៧កក្កដា ២០០៤*

*សូយ ឡូត*